**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សាលក្រមរដ្ឋប្បវេណីលេខ ៤៦ (ជ)
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ដែលមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ ២០៣ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ ដែលមាន ៖

ដើមចោទឈ្មោះ [redacted] ភ័ក្រ្តា ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៣០៦៤១០៣២ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ អាសយដ្ឋានបច្ចុប្បន្ន[redacted]។

-មានលោកស្រី [redacted] អត្តលេខ ១៦០៣ ,លោកស្រី [redacted] អត្តលេខ ២៣៤៣T , លោកស្រី[redacted] អត្តលេខ ២២៣៦ និងលោក [redacted] ក្លិប អត្តលេខ ២៤៥២T ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

ចុងចម្លើយឈ្មោះ [redacted] វដ្ឋា ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៣០៤៨៥០៥០ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ អាសយដ្ឋានបច្ចុប្បន្ននៅ[redacted] សេដ្ឋ ខេត្តកំពង់ស្ពឺ។

## អង្គហេតុ និងចំណុចវិវាទ

### ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១.សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] វដ្ឋា

២.កំណត់យកដើមចោទឈ្មោះ [redacted] ភ័ក្រ្តា ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ហួ រតនាណាហ្វេម ភេទប្រុស កើតថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ដែលមានសំបុត្រកំណើតលេខ ៧៣ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ ។

៣.បង្គាប់ឲ្យចុងចម្លើយប្រគល់ម៉ូតូម៉ាកហុងដាស្កូបពីអាយ (HONDA SCOOPY-i) ផលិតឆ្នាំ២០១៩ ពណ៌ស មានស្លាកលេខភ្នំពេញ ១N-៣៥៥៣ ឲ្យទៅដើមចោទជាម្ចាស់កម្មសិទ្ធិផ្តាច់មុខ ។

៤.បង្គាប់ឲ្យចុងចម្លើយបង់សោហ៊ុយចិញ្ចឹមបីបាច់ថែរក្សាកូនចំនួន ៣០០ (បីរយ)ដុល្លារអាមេរិកក្នុង ០១ (មួយ)ខែ រហូតកូនដល់នីតិភាព ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។



Scanned with CamScanner

## ខ.ការពន្យល់គ្រួសៗអំពីរឿង

ដើមចោទឈ្មោះ [redacted] ភ័ត្រា បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយចុងចម្លើយឈ្មោះ [redacted] វឌ្ឍា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ២៣ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។ ក្នុងរយៈពេលជាង ០៤ (បួន)ឆ្នាំ នៃការរួមរស់នៅជាមួយគ្នាជាប្ដីប្រពន្ធរវាង ដើមចោទ និងចុងចម្លើយតែងតែមានភាពរកាំរកូស និងមិនចុះសម្រុងនឹងគ្នា ព្រោះចុងចម្លើយជាមនុស្សដែលប្រកាន់ច្រើន ហើយតែងតែជេរប្រមាថ តិះដៀល និងរករឿងឈ្លោះប្រកែកជាមួយដើមចោទ ជារឿយៗ ហើយដើមចោទតែងតែស៊ូទ្រាំ និងអនុគ្រោះទៅលើទង្វើរបស់ចុងចម្លើយជាច្រើនដង ។ជាពិសេស ០១ (មួយ)ឆ្នាំចុងក្រោយនេះ ចុងចម្លើយមានអាកប្បកិរិយាធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់ដើមចោទយ៉ាងខ្លាំង ។ជាក់ស្ដែងនៅក្នុងអំឡុងខែកញ្ញា ឆ្នាំ២០២០ ចុងចម្លើយបានប្រាប់ដើមចោទថា គាត់ចង់ទិញឡានដឹកដី០១គ្រឿង ដើម្បីឲ្យឪពុកម្ដាយគាត់រកស៊ី ហើយដើមចោទក៏ផ្ដល់យោបល់ថា កុំទាន់ទិញឡានដឹកដីអីបង ព្រោះយើងមិនទាន់មានលុយគ្រប់គ្រាន់ ហើយជីវភាពគ្រួសាររបស់យើងក៏នៅទន់ខ្សោយនៅឡើយ ចំណែកកូនយើងវិញក៏នៅតូចទៀតដែលត្រូវចិញ្ចឹមបីបាច់ថែរក្សាឲ្យបានល្អ ចាំពេលបងត្រឡប់មកពីធ្វើការវិញនៅប្រទេសកូរ៉េវិញ ចាំទិញជូនគាត់ទៅអូនមិនជំទាស់ទេ ។ពេលនោះចុងចម្លើយបានស្រែកទាំងកំហឹងមកកាន់ខ្លួនថា នៅផ្ទះមើលតែកូនទៅ កុំចេះលូកមាត់រឿងលុយគេ កុំចេះចាត់ចែងលុយគេ គេជាអ្នករក បើខ្លាំងរកលុយប្រហែលគេទៅ ចាំផ្ដល់យោបល់ ។ បន្ទាប់ពីដើមចោទបានផ្ដល់យោលបល់បែបនេះ ទៅកាន់ចុងចម្លើយហើយ ចុងចម្លើយក៏ផ្ដាច់ទំនាក់ទំនង ជាមួយដើមចោទ និងឈប់ផ្ដល់លុយកាក់ដែលខ្លួនរកបានរៀងរាល់ខែចំនួន ១៥.០០០ (មួយពាន់ប្រាំរយ)ដុល្លារអាមេរិក ដើម្បីផ្គត់ផ្គង់ទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាខ្លួន និង កូនដូចមុន គឺចាប់តាំងពីខែតុលា ឆ្នាំ២០២០ រហូតដល់ពេលបច្ចុប្បន្ននេះ ។លុះនៅក្នុងអំឡុងខែធ្នូ ឆ្នាំ២០២០ ចុងចម្លើយបានទិញឡានដឹកដីជូនឪពុកម្ដាយគាត់ដូចអ្វីដែលចុងចម្លើយបាននិយាយកន្លងមក ។ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយមានកូនប្រុសចំនួន ០១ នាក់ឈ្មោះ [redacted] រតនាណាហ្វេម អាយុ៣ឆ្នាំ ភេទប្រុស កើតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ។ដើមចោទ និងចុងចម្លើយមានទ្រព្យរួម គឺម៉ូតូម៉ាកហុងដាស្កុបពីអាយ ផលិតឆ្នាំ២០១៨ ពណ៌ស មានផ្លាកលេខភ្នំពេញ ១N-៣៥៥៣ ចំនួន ០១ (មួយ)គ្រឿង ។

## គ.អង្គហេតុនៃការអះអាងរបស់សាមីភាគី

-ដើមចោទឈ្មោះ [redacted] ភ័ត្រា បានអះអាងថា ចំពោះមូលហេតុនៃការលែងលះ គឺដោយសារតែខ្លួន និងចុងចម្លើយ លែងមានមនោសញ្ចេតនាជាប្ដីប្រពន្ធនឹងគ្នាទៀតហើយ ព្រោះចុងចម្លើយជាមនុស្សដែលប្រកាន់ច្រើន ហើយតែងតែជេរប្រមាថ តិះដៀល និងរករឿងឈ្លោះប្រកែកជាមួយគ្នាខ្លួនជារឿយៗ។ ខ្លួនតែងតែស៊ូទ្រាំ និងអនុគ្រោះទៅលើទង្វើរបស់ចុងចម្លើយជាច្រើនលើកច្រើនសារ ប៉ុន្តែខាងចុងចម្លើយនៅតែមិនព្រមកែប្រែអត្តចរិត ។ ជាពិសេសគិតមកដល់ពេលបច្ចុប្បន្ននេះអស់រយៈពេល ០២ (ពីរ)ឆ្នាំហើយ ចុងចម្លើយបានផ្ដាច់ទំនាក់ទំនងជាមួយខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ និងឈប់ផ្ដល់លុយកាក់ដែលរកបានជារៀងរាល់ខែឲ្យខ្លួនដើម្បីផ្គត់ផ្គង់ទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាខ្លួន និងកូនដូចមុន ។ បច្ចុប្បន្នខ្លួនមានមុខរបរជាជាងសាឡន ។

-ចុងចម្លើយឈ្មោះ [redacted] វឌ្ឍា អវត្តមានដោយគ្មានមូលហេតុត្រឹមត្រូវ ដែលតុលាការបានធ្វើការកោះហៅមកចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តាមនីតិវិធីច្បាប់ ប៉ុន្តែត្រូវបានម្ដាយរបស់ចុងចម្លើយផ្ដិតម្រាមដៃទទួលជំនួស ។

## ង.ចំណុចវិវាទ

-តើមានមូលហេតុនៃការលែងលះដែលឬទេ?

-តើដើមចោទមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលយកសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] រតនាណាហ្វេម ដែរទេ?

-អំពីសោហ៊ុយនៃការចិញ្ចឹមកូន តើត្រូវសម្រេចយ៉ាងដូចម្តេច?

-តើដើមចោទមានសិទ្ធិកម្មសិទ្ធិ លើម៉ូតូម៉ាកស្កុបពីអាយ (HONDA SCOOPY-I) ដែលឬទេ?

## ៦.ភស្តុតាងដែលដាក់ដោយភាគីដើមចោទ

-សំបុត្រអាពាហ៍ពិពាហ៍លេខ ២៣ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧ ។

-សំបុត្រកំណើតលេខ ៧៣ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ ។

-ប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ។

-សៀវភៅស្នាក់នៅរបស់ឈ្មោះ [redacted] រដ្ឋា លេខ ៣៧៦៨០ប.ស ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យភស្តុតាងតុលាការយល់ឃើញថា ៖

១.ដើមចោទឈ្មោះ [redacted] ភ័ក្រ្តា បានអះអាងថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយចុងចម្លើយឈ្មោះ [redacted] រដ្ឋា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧ ។តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ២៣ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ឃុំបរសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ឃើញថា ដើមចោទពិតជាប្តីប្រពន្ធស្របតាមច្បាប់ប្រាកដមែន ។

២.ដើមចោទឈ្មោះ [redacted] ភ័ក្រ្តា បានអះអាងថា ក្នុងចំណងអាពាហ៍ពិពាហ៍ ខ្លួន និងចុងចម្លើយបង្កើតបានកូនប្រុសចំនួន ០១ នាក់ ឈ្មោះ [redacted] រតនាណាហ្សែម មានអាយុចំនួន ០៣ឆ្នាំ តាមសំបុត្រកំណើតលេខ ៧៣ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] រតនាណាហ្សែម ឃើញថា ឈ្មោះ [redacted] រតនាណាហ្សែម កើតថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ពិតជាកូនរបស់ដើមចោទ និងចុងចម្លើយ ប្រាកដមែន ។

៣.ដើមចោទឈ្មោះ [redacted] ភ័ក្រ្តា បានអះអាងថា គិតមកដល់ពេលបច្ចុប្បន្ននេះអស់រយៈពេល ០២ (ពីរ) ឆ្នាំហើយ ចុងចម្លើយបានផ្តាច់ទំនាក់ទំនងជាមួយខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ និងឈប់ផ្តល់លុយកាក់ដែលរកបានជារៀងរាល់ខែឲ្យខ្លួន ដើម្បីផ្គត់ផ្គង់ទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាខ្លួន និងកូនដូចមុន ។ បច្ចុប្បន្នខ្លួនមានមុខរបរជាជាងសាឡន ។ ចុងចម្លើយអវត្តមានដោយពុំមានមូលហេតុ ។

៤.ដើមចោទឈ្មោះ [redacted] ភ័ក្រ្តា បានអះអាងថាមូលហេតុនៃការលែងលះ គឺដោយសារតែខ្លួន និងចុងចម្លើយលែងមានមនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ព្រោះចុងចម្លើយជាមនុស្សដែលប្រកាន់ច្រើន ហើយតែងតែជេរប្រមាថ តិះដៀល និងរករឿងឈ្លោះប្រកែកជាមួយគ្នាខ្លួនជារឿយៗ។ ខ្លួនតែងតែស៊ូទ្រាំ និងអនុគ្រោះទៅលើទង្វើរបស់ចុងចម្លើយជាច្រើនលើកច្រើនសារ ប៉ុន្តែខាងចុងចម្លើយនៅតែមិនព្រមកែប្រែអត្តចរិត ។ ចុងចម្លើយអវត្តមានដោយគ្មានមូលហេតុត្រឹមត្រូវទោះបីតុលាការបានធ្វើការកោះហៅមកចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តាមនីតិវិធីច្បាប់ ។

៥.ដើមចោទឈ្មោះ [redacted] ភ័ក្រ្តា បានអះអាងថា ខ្លួនមានទ្រព្យរួមជាម៉ូតូម៉ាកហុងដាស្កុបពីអាយ ផលិតឆ្នាំ២០១៩ ពណ៌ស មានផ្លាកលេខភ្នំពេញ ១N-៣៥៥៣ ចំនួន ០១ (មួយ)គ្រឿង ។ចុងចម្លើយអវត្តមានដោយគ្មានមូលហេតុត្រឹមត្រូវ ។ប៉ុន្តែតាមសេចក្តីបំភ្លឺ និងឆ្លើយតបបណ្តឹងទាមទារ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ត្រង់ចំណុច (គ) របស់ចុងចម្លើយឈ្មោះ [redacted] រដ្ឋា ឃើញថា បានយល់ព្រមប្រគល់ប្រគល់ម៉ូតូម៉ាកហុងដាស្កុបពីអាយ (Scoopy i) ផលិតឆ្នាំ២០១៩ ពណ៌ស មានផ្លាកលេខភ្នំពេញ ១N-៣៥៥៣ ចំនួន ០១ (មួយ)គ្រឿង ឲ្យទៅដើមចោទជាអ្នកមានកម្មសិទ្ធិផ្តាច់មុខ ។ ដូចនេះគប្បីតុលាការសម្រេចប្រគល់ម៉ូតូម៉ាកហុងដាស្កុបពីអាយ (Scoopy i) ផលិតឆ្នាំ២០១៩ ពណ៌ស មានផ្លាកលេខភ្នំពេញ ១N-៣៥៥៣ ឲ្យទៅដើមចោទជាអ្នកមានសិទ្ធិកម្មសិទ្ធិ ។



Scanned with CamScanner

៦.ដើមចោទឈ្មោះ [redacted] ភ័ត្រា បានស្នើសុំលែងលះពីចុងចម្លើយ ដោយមូលហេតុអស់មនោសញ្ចេតនាជាមួយចុងចម្លើយឈ្មោះ [redacted] វណ្ណា ឃើញថា មានលក្ខណៈសមហេតុផល ដែលអាចឱ្យតុលាការទទួលយកមកពិចារណាតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

៧.ដើមចោទឈ្មោះ [redacted] ភ័ត្រា ស្នើសុំកំណត់យកខ្លួនជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] រតនាណាហ្វេម ដោយអះអាងថាខ្លួនមានមុខរបរជាជាងសាឡន អាចចិញ្ចឹមកូនតែម្នាក់ឯងបាន ។ ដូច្នេះគប្បីសម្រេចប្រគល់អំណាចមេបាឱ្យទៅដើមចោទ ដោយហេតុថាកូននៅតូច ទើបតែអាយុ៣ឆ្នាំ ហើយបច្ចុប្បន្នដើមចោទរស់នៅជាមួយកូនស្រាប់ ងាយស្រួលក្នុងការមើលថែទាំងកូនបានល្អជាងចុងចម្លើយ ។

៨.ដើមចោទឈ្មោះ [redacted] ភ័ត្រា ស្នើសុំទាមទារឱ្យចុងចម្លើយបង់សោហ៊ុយចិញ្ចឹមចំនួន ៣០០ ដុល្លារអាមេរិក ក្នុងមួយខែ ប៉ុន្តែនៅក្នុងពេលដំណើរការនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទយល់ព្រមទទួលយកចំនួន ៥០ (ហាសិប) ដុល្លារអាមេរិក ក្នុងមួយខែ ។

៩.ប្រាក់ប្រដាប់ក្តី គប្បីសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ហេតុដូច្នេះសម្រេច

១.ឱ្យដើមចោទឈ្មោះ [redacted] ភ័ត្រា ភេទស្រី អាយុ២៣ឆ្នាំ លែងលះពីចុងចម្លើយឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ២៧ឆ្នាំ ចាប់ពីពេលនេះតទៅ ។

២.កំណត់យកដើមចោទឈ្មោះ [redacted] ភ័ត្រា ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] រតនាណាហ្វេម ភេទប្រុស កើតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ រហូតដល់កូនដល់នីតិភាព ។

៣.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណា បង់អាហារកាតព្វកិច្ចចិញ្ចឹមកូនឈ្មោះ [redacted] រតនាណាហ្វេម ចំនួន ៥០ (ហាសិប) ដុល្លារអាមេរិក ក្នុងមួយខែ រហូតដល់កូនដល់នីតិភាព ។ ផ្តល់សិទ្ធិឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណា ដែលមិនមានអំណាចមេបាលើកូន មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូនរហូតដល់កូនដល់នីតិភាព ។

៤.ប្រគល់ម៉ូតូម៉ាកហុងដាស្កូបពីអាយ (HONDA SCOOPY-I) ផលិតឆ្នាំ២០១៩ ពណ៌ស មានស្លាកលេខភ្នំពេញ ១N-៣៥៥៣ ទៅដើមចោទឈ្មោះ [redacted] ភ័ត្រា ជាអ្នកមានសិទ្ធិលើកម្មសិទ្ធិ ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ។

កំពង់ស្ពឺ,ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា៖ [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។
ថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
កំពង់ស្ពឺ,ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner